# អន្ធជាតក

## ( សម្តេងពីរបស់ចោកាបំផុតជាំងបី )



*ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធជនទាំងពីរនាក់នោះ (ទេវទត្ត និងកោកាលិកភិក្ខុ) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឧសភស្សេវ តេ ខន្ធោ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវបច្ចុប្បន្ន ដូចគ្នានឹងជាតកខាងដើម (ជម្ពុខាទកជាតក) ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតជា**ឯរណ្ឌរុក្ខទេវតា** (ទេវតានៅនឹងដើមល្ហុងប្រេង) ដែលនៅក្នុងឧបចារៈស្រុក*

*មួយ ។ គ្រានោះ ពួកមនុស្សនាំគ្នាអូសគោចាស់ដែលស្លាប់ក្នុងស្រុកមួយ យកទៅចោលក្នុងព្រៃល្ហុង ដែលនៅខាងក្រៅស្រុក ។ មានចចកមួយមកស៊ីសាច់គោនោះ ។ មានក្អែកមួយមកហើយ ពួនលើដើមល្ហុង ឃើញចចកនោះ រួចគិតថា ប្រសិនបើយើងពោលសរសើរគុណដែលមិនមាន របស់ចចកនោះ យើងគប្បីបានស៊ីសាច់ ដូច្នេះហើយ ទើបពោលគាថាទី ១ ថា*

**ឧសភស្សេវ តេ ខន្ធោ, សីហស្សេវ វិជម្ភិតំ,**
**មិគរាជ ឆមោ ត្យត្ថុ, អបិ កិញ្ចិ លភាមសេ។**

*ករបស់អ្នក ដូចជាកនៃគោឧសភៈ ការមិតពត់របស់អ្នក ដូចជាការមិតពត់នៃសត្វ សីហៈ បពិត្រមិគរាជ ខ្ញុំសូមថ្វាយបង្គំអ្នក ធ្វើម្ដេច ខ្ញុំនឹងបានសាច់តិចតួច ។*

*បទថា* **ឆមោ ត្យត្ថុ** *កាត់បទថា* **នមោ តេ អត្ថុ** *ប្រែថា ការថ្វាយបង្គំចូរមានដល់លោក ។*

*ចចកស្ដាប់ពាក្យនោះហើយ ពោលគាថាទី ២ ថា*

**កុលបុត្តោវ ជានាតិ, កុលបុត្តំ បសំសិតុំ;**
**មយូរគីវសង្កាស, ឥតោ បរិយាហិ វាយស។**

*កុលបុត្រចេះសរសើរនូវកុលបុត្រដូចគ្នា ម្នាលក្អែកមានផ្នូតកដូចជាក្ងោក អ្នកចូរចុះអំពីដើមល្ហុងនេះមក ។*

*បទថា* **ឥតោ បរិយាហិ** *សេចក្ដីថា ចចកពោលថា អ្នកចុះពីដើមល្ហុង ហើយចូរមកស៊ីសាច់ចុះ ។*

*រុក្ខទេវតាឃើញកិរិយារបស់សត្វទាំងនោះហើយ ទើបពោលគាថាទី ៣ ថា*

**មិគានំ សិង្គាលោ អន្តោ, បក្ខីនំ បន វាយសោ;**

**ឯរណ្ណោ អណ្ឌោ រុក្ខោធំ, តយោ អណ្ឌា សមាគតា។**

*ចចកជាសត្វថោកទាប ជាងម្រឹគទាំងឡាយ ឯក្អែកជាសត្វថោកទាប ជាងបក្សីទាំងឡាយដែរ ដើមល្ហុងជាឈើថោកទាបជាងឈើទាំងឡាយ ពួកថោកទាបទាំង ៣ មកជួបប្រទះគ្នា ។*

*បទថា* **អណ្ឌោ** *បានដល់ ហីនោ លាមកោ ប្រែថា ថោកទាប អាក្រក់ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា សិង្គាលោ ទេវទត្តោ អហោសិ** *ចចកក្នុងកាលនោះ បានមកជាទេវទត្ត*

**កាកោ កោកាលិកោ** *ក្អែកបានមកជាកោកាលិកភិក្ខុ*

**រុក្ខទេវតា បន អហមេវ អហោសិំ** *ចំណែករុក្ខទេវតា គឺ តថាគតនេះឯង ។*

*អណ្ឌជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត កុម្ភវគ្គ បិដកលេខ ៥៨ ទំព័រទី ១៧៩)*

*ថ្ងៃ សុក្រ ១៤ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១០ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ជ.វ.ថ*